ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ::៤៥៨/២២-៦-០៦

សាលដីកា

លេខ:៣៨ ខ/០៣-៤-០៨

នាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាសាលាឧទ្ធរណ៍ នៅថ្ងៃទី ០៣-៤-២០០៨ ដោយមានសមាសភា ដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១- លោក [redacted] ជាប្រធាន

២- លោក [redacted] ជាចៅក្រម

៣- លោក [redacted] ជាចៅក្រម

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

**១- ជនជាប់ចោទឈ្មោះ** [redacted] **ភារម្យ ហៅ ជេម ហៅ ខែល** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរៈគ្មាន ទីលំនៅមុនពេលច[redacted] សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោ[redacted] "រ" ម្តាយឈ្មោះ [redacted] "ស" នៅលីវ ទោសពីមុនៈមាន ចាប់ខ្លួនថ្ងៃទី០៥-៨-០៥. ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅ ពន្ធនាគារព្រៃស ម១ ។

**២- ជនជាប់ចោទឈ្មោះ** [redacted] **សុធារុធ ហៅ ទី ហៅ តាប់** ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរៈ ជាងម៉ាស៊ីនត្រជាក់ ទីលំនៅមុនពេលចាប់ខ្លួន[redacted] សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោ[redacted] "រ" នៅលីវ ទោសពីមុនៈមាន ចាប់ខ្លួនថ្ងៃទី០៥-៨-០៥ ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅ ពន្ធនាគារត្រពាំងផ្លុង ម៣ ។

**<u>ត្រូវចោទពីបទៈ</u>** "ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៤-៧-០៥ តាមមាត្រា៦. ២០ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ស្តីពីការត្រួតពិនិត្យអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ ។

**៣- ជនជាប់ចោទឈ្មោះ**[redacted] **សុវណ្ណ ហៅ ប្ញូរ** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរៈ រត់ម៉ូតូឌុប ទីលំនៅមុនពេលចាប់ ,

ខ្ទូនផ្ទះលេ[redacted] គោកបញ្ចប់ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ[redacted] មានកូន០២នាក់ ទោសពីមុនមាន ចាប់ខ្លួនថ្ងៃទី០៥-៨-២០០៥. ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១។

**៤- ជនជាប់ចោទឈ្មោះ** [redacted] **ព្រឹម** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរៈ ជាងជួសជុលម៉ូតូ ទីលំនៅមុនពេល [redacted] ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ[redacted] "រ" ប្រពន្ធឈ្មោះ[redacted] មានកូន០២នាក់ ទោសពីមុនមាន ចាប់ខ្លួនថ្ងៃទី០៥-៨-២០០៥ ឃុំខ្លួនថ្ងៃទី១២-៨-២០០៥ បច្ចុប្បន្ននៅពន្ធនាគារ ព្រៃស ម១។

<u>**ផ្លូវទោសទីបទៈ**</u> "ទទួលផលចោរកម្ម" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៤-៧-២០០៥ តាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**[redacted] **លីណា** ភេទស្រី អាយុ៤០ឆ្នាំ មុខរបរៈលក់គ្រឿងសំណង់ សព្វថ្ងៃរស់នៅផ្ទះលេខ៩៧ ផ្លូវ៤៧០ ក្រុម៧ សង្កាត់ទួលទំពូងII ខណ្ឌចំការមន ក្រុងភ្នំពេញ។

តាមបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ**, បណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ**, បណ្តឹងឧទ្ធរណ៍លេខ ៩២ ចុះថ្ងៃទី០៧-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ព្រឹម** និងបណ្តឹងឧទ្ធរណ៍លេខ ១០៨ ចុះថ្ងៃទី១៥-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **សុធាវុធ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខៈ១៣ "ច" ចុះថ្ងៃទី១៧-០១-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ** គ្រប់ចំណុចទាំងមូល។

## <u>ដំណើររឿងមានដូចតទៅៈ</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី២៤-៧-២០០៥ របស់ឈ្មោះ [redacted] **លីណា** ប្តឹងថាៈ កាលពីថ្ងៃទី២៤-៨-២០០៥ វេលាម៉ោង ១២ និង១៥នាទី ថ្ងៃត្រង់ ខ្លួនជិះម៉ូតូម៉ាកគុបស្ទូតពណ៌ទឹកប៊ិច ផ្លាកលេខ 1D ៩២២៣ លេខតួ C៧0 ១៣០៦២៥៨ លេខម៉ាស៊ីន C៧0E ១២៦៦០២០ ដ[redacted] បំរុងចូលស្រាប់តែជនល្មើស ២នាក់ជិះម៉ូតូពណ៌ស្វែមកឈប់ពីក្រោយ ម្នាក់ជិះខាងក្រោយលោតចុះដកកាំភ្លើងភ្ជង់សៀតផ្កាខាងស្តាំ ដេញខ្លួនឱ្យចុះ ហើយយកម៉ូតូខ្លួនជិះគេចខ្លួនបាត់។

**- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៣ "ច" ចុះថ្ងៃទី ១៧-០១-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :**

១- កែតម្រូវមាត្រានៃបទចោទលើឈ្មោះ[redacted] **ភារម្យ ហៅ ខែល ហៅ ដេម និង ឈ្មោះ** [redacted] **សុធាវុធ ហៅ ទី ហៅ តាប់** ចំពោះបទប្រើប្រាស់អាវុធខុសច្បាប់ ពីមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ទៅមាត្រា២០ នៃច្បាប់ស្តីពីការត្រួតពិនិត្យអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលប្រកាសឱ្យប្រើជាកិច្ចការប្រញាប់តាមព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១-៦-២០០៥ តាមអំណាចមាត្រា១០៥ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

២- ឱ្យឈ្មោះ[redacted] **សុវណ្ណ**, ឈ្មោះ[redacted] **ព្រឹម** និង ឈ្មោះ[redacted] **គីមស្រ៊ី** បានរួចផុតពីបទចោទ សមគំនិតក្នុងអំពើប្លន់

ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៤-៧-០៥ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦៩ . មាត្រា៦ នៃច្បា ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្តីពីស្ថានទម្ងន់ទោសបទឧក្រិដ្ឋ តាមមាត្រា១៥២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

៣- ផ្តន្ទាទោស :

ក- ឈ្មោះ [redacted]ភារម្យ ហៅ ទែល ហៅ ជេម ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ[redacted] ហៅ ហៅតាប់ ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់០៦ឆ្នាំ "ប្រាំមួយឆ្នាំ" គិតពីថ្ងៃអនុវត្តសាលក្រមពីមុនៗ ចប់ និ ពិន័យជាប្រាក់ក្នុងម្នាក់ៗ ៥០ "ហាសិប" ម៉ឺនរៀល ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃ ២៤-៧-២០០៥ តាមមាត្រា៦ និងមាត្រា២០ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ស្តីពីការត្រួតពិនិត្យអាវុ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ។ ក្នុងករណីមិនព្រមបង់ប្រាក់ធនទណ្ឌនេះ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា៧ និងមាត្រា១០ នៃ ច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

ខ- ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ព្រឹម ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ០១ "មួយ" ឆ្នាំ គិតពីថ្ងៃឃុំខ្លួ ថ្ងៃទី១២-៨-២០០៥ ពីបទទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤-៧-២០០៥ តាមមាត្រា ៥១ នៃច្បាប ព្រហ្មទណ្ឌអន្តរកាល ។

គ- ឈ្មោះ[redacted] **គីម ស្រ៊ី** ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ "មួយ" ឆ្នាំ ប៉ុន្តែ ទោសនេះត្រូវព្យួររយៈ ពេលសាកល្បង ០៥ "ប្រាំ" ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤-៧-២០០៥ តាមមាត្រា ៥១ និងមាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-វត្ថុតាងមានអាវុធខ្លីមួយដើម ម៉ាករ៉ូឡូពីរអ៊ីញលេខ១៣៧៥២ និងគ្រាប់ចំនួន០៥ "ប្រាំ" គ្រាប់ ត្រូវរឹបអូសបំផ្លាញចោល

៥-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ភារម្យ, ឈ្មោះ [redacted] សុធាវុធ ឈ្មោះ [redacted] សុវណ្ណ, ឈ្មោះ[redacted] ព្រឹម និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គីមស្រ៊ី និងដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted]ភារម្យ, បណ្តឹងឧទ្ធរណ៍ លេខ៤៩ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] សុវណ្ណ, បណ្តឹងឧទ្ធរណ៍លេខ៩២ ចុះថ្ងៃទី០៧-៣-២០០៦ របស់ ជនជាប់ចោទឈ្មោះ [redacted] ព្រឹម និងបណ្តឹងឧទ្ធរណ៍លេខ ១០៨ ចុះថ្ងៃទី១៥-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted]សុធាវុធ **ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខៈ១៣ "ច" ចុះថ្ងៃទី១៧-០១-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ** គ្រប់ចំណុចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៩-៣-២០០៧ របស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។
- បានឃើញរបាយការណ៍រឿងចុះថ្ងៃទី០៦-១១-២០០៧ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍រឿង

- ជនជាប់ចោទឈ្មោះ[redacted]ភារម្យ ឆ្លើយថា: នៅថ្ងៃទី២៤-៧-២០០៥ ខ្លួនបានប្លន់ម៉ូតូគុបសេ៧០ ពណ៌ទឹកប៊ិច នៅ

ទូលទំពូង រួចយកទៅលក់ឱ្យ[redacted]សុវណ្ណ ។ សំណូមពរ សុំបន្ធូរបន្ថយទោសដល់រូបខ្លួន ។

- ជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ ឆ្លើយថា: នៅថ្ងៃទី២៤-៧-២០០៥ ខ្លួនមិនបានប្រព្រឹត្តទេ, ខ្លួនធ្លាប់បានទិញម៉ូតូពី[redacted] ភារម្យ តែ ម្តងគត់ ។ សំណូមពរ សុំលើកលែងចោទប្រកាន់ដល់រូបខ្លួន ។

- ជនជាប់ចោទឈ្មោះ[redacted] ព្រីម ឆ្លើថា: ខ្លួនធ្លាប់ទិញម៉ូតូពី[redacted] សុវណ្ណ មួយគ្រឿង ។ សំណូមពរ សុំលើកលែងចោ ប្រកាន់ដល់រូបខ្លួន ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់

២- តម្កល់សាលក្រមតុលាការក្រុងភ្នំពេញ ដែលសម្រេចផ្តន្ទាទោសក្នុងកំរិតអប្បបរិមានៃទោសនេះ ទុកជាត្រឹមត្រូវ និងបានការតទៅ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្នុងរឿងនេះ អង្គហេតុបញ្ជាក់ថាជនជាប់ចោទប្លន់បានម៉ូតូម៉ាកគុប៧០ ពណ៌ទឹកប៊ិច ហើយកូនក្តីខ្លួនបានទិញម៉ូតូតែមួយគ្រឿងទេ តែគ្រប់រឿងឱ្យតែមានម៉ូតូម៉ាកគុប៧០ គឺមានឈ្មោះកូនក្តីខ្លួនទាំងអស់ ។ រឿងនេះមានការភន្តច្រឡំ ព្រោះតុលាការបានធ្វើការផ្តន្ទាទោសជនជាប់ចោទរួចហើយ. សូមធ្វើការលើកលែងចោទដល់កូនក្តីខ្លួន [redacted] សុវណ្ណ និងសូមបន្ធូរបន្ថយទោសដល់ឈ្មោះ [redacted] ភារម្យ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា:

- **យល់ឃើញថា:** បណ្តឹងឧទ្ធរណ៍លេខ៨៤៨ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **ភារម្យ**. បណ្តឹងឧទ្ធរណ៍លេខ៨៤៩ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោ[redacted] **សុវណ្ណ**. បណ្តឹងឧទ្ធរណ៍លេខ៩២ ចុះថ្ងៃទី០៧-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **ព្រីម** និងបណ្តឹងឧទ្ធរណ៍លេខ១០៨ ចុះថ្ងៃទី១៥-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **សុធារ៉ុធ** ធ្វើឡើងនៅក្នុងកំណត់ច្បាប់.

- **យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] **ភារម្យ** និង [redacted] **សុធារ៉ុធ** ថា កាលពីថ្ងៃទី២៤-៧-២០០៥ ខ្លួនបានប្លន់ម៉ូតូ C៧០ ពណ៌ទឹកប៊ិចនៅទួលទំពូង២ រួចយកទៅលក់ឱ្យ[redacted] សុវណ្ណ. ក្នុងសកម្មភាពប្លន់ ខ្លួ[redacted] សុធារ៉ុធ ជិះម៉ូតូឌុប[redacted] ភារម្យ តាមស្រីរងគ្រោះរហូតដល់មុខផ្ទ[redacted] ភារម្យក្លង់យកម៉ូតូ ។

ឯជនជាប់ចោទឈ្មោ[redacted]សុវណ្ណ ថាខ្លួនបានទិញម៉ូតូពី[redacted] ភារម្យ ហើយលក់ឱ្យ[redacted] ព្រីម. [redacted]ព្រីមថា ខ្លួនដឹងថានោះជាម៉ូតូចោរប្លន់ដែរតែខ្លួននៅតែទិញពី[redacted] សុវណ្ណ ។

-យល់ឃើញថា: សាលាដំបូងភ្នំពេញ បានលើកសំអាងហេតុ មកបញ្ជាក់ច្បាស់លាស់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍មិនលើកសំអាងហេតុដដែលនោះឡើងវិញទៀតទេ ។

-យល់ឃើញថា: សាលក្រមព្រហ្មទណ្ឌលេខ ១៣ "ច" ចុះថ្ងៃទី១៧-០១-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

## **ហេតុដូចនេះវិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ៤៨ ចុះថ្ងៃទី ០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] **ភារម្យ** , បណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី០៣-០២-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណ** , បណ្តឹងឧទ្ធរណ៍លេខ ៩២ ចុះថ្ងៃទី០៧-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ព្រឹម** និង បណ្តឹងឧទ្ធរណ៍លេខ១០៨ ចុះថ្ងៃទី ១៥-៣-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **សុធាវុធ** ទុកជាត្រឹមត្រូវតាម ទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៣ "ច" ចុះថ្ងៃទី១៧-០១-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញទុកជាបានការ ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ.

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ[redacted] **ភារម្យ** , [redacted] **សុវណ្ណ**, [redacted] **ព្រឹម** និងមេធាវីការពារជនជាប់ចោទ, កំបាំងមុខជនជាប់ចោទ [redacted] **សុធាវុធ** , ដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះ ចូលជាស្ថាពរមានអានុភាពអនុវត្តតែទៅលើឈ្មោះ [redacted] ភារម្យ និងឈ្មោះ [redacted] ព្រឹម ប៉ុណ្ណោះ ក្រៅពីនេះមិនទាន់មានអានុភាពអនុវត្តឡើយ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

.................................................................................................

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤

ក្រឡាបញ្ជី